# សេចក្តីជូនដំណឹង

## ម្ចាស់រោងចក្រ-សិប្បកម្ម និងសហគ្រាសធុនតូច និងមធ្យមសូមជ្រាប

តាមរយៈធនាគារអភិវឌ្ឍន៍អាស៊ីADB ក្រោមគម្រោងមូលនិធិអភិវឌ្ឍន៍បច្ចេកវិទ្យា (Technology Development Fund-TDF) អគ្គយកដ្ឋានឧស្សាហកម្មនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សូមជម្រាបជូនដំណឹងដល់ **ម្ចាស់រោងចក្រ-សិប្បកម្ម និងសហគ្រាសធុនតូច និងមធ្យម** ឲ្យបានជ្រាបដូចខាងក្រោមៈ

មូលនិធិអភិវឌ្ឍន៍បច្ចេកវិទ្យា(TDF) គឺជាគម្រោងសាកល្បងដែលធ្វើឡើងរួមគ្នាដោយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលក្នុងគោលបំណងបង្កើនភាពប្រកួតប្រជែងរបស់សហគ្រាសធុនតូច និង មធ្យម(SMEs) ដែលស្ថិតនៅក្នុងវិស័យកែច្នៃម្ហូបអាហារដោយជួយពួកគេអោយមានភាពប្រកួតប្រជែងកាន់តែប្រសើរឡើងតាមរយៈការអភិវឌ្ឍន៍បច្ចេកវិទ្យា និងការណែនាំអំពីប្រព័ន្ធគ្រប់គ្រងលំដាប់ថ្នាក់ពិភពលោក។ មូលនិធិនេះជាមូលនិធិគ្មានសំណងដែលនឹងត្រូវផ្តល់ដល់គម្រោងរបស់SMEs ណាដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។ មូលនិធិនេះនឹងត្រូវផ្តល់ជូនតាមលក្ខណៈទូទាត់ជាដំណាក់កាលដែលអាចផ្តល់ជូនថវិកាចាប់ពី ៥,០០០ ដល់ ៣០,០០០ ដុល្លាអាមេរិក ដោយសហគ្រាសធុនតូចនិងមធ្យមត្រូវរួមចំណែកបដិភាគយ៉ាងតិចបំផុត៥០%នៃការចំណាយលើគម្រោងនេះ។ ពិសេសជាងនេះទៅទៀតមូលនិធិអភិវឌ្ឍន៍បច្ចេកវិទ្យានឹងផ្តល់ជូនសហគ្រាសណាដែលមានម្ចាស់ រឺ អ្នកគ្រប់គ្រងជា ស្រ្តីតាមកូតា ៤០-៤៥%។

ដូចនេះក្រុមការងារយើងខ្ញុំ សូមអញ្ជើញម្ចាស់រោងចក្រ-សិប្បកម្ម និងសហគ្រាសធុនតូច និងមធ្យមទាំងអស់ដែលចង់ទទួលបានជំនួយគាំទ្រពីមូលនិធិអភិវឌ្ឍន៍បច្ចេកវិទ្យា មកទទួលយកឯកសារពាក្យស្នើសុំនៅលេខាធិការដ្ឋាននៃអនុគណៈកម្មាធិការសហគ្រាសធុនតូចនិងមធ្យមSMEs ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ ហើយសូមមកដាក់ពាក្យស្នើសុំវិញចាប់ពី**ថ្ងៃទី ០៣ ដល់ថ្ងៃទី២០ ខែមករា ឆ្នាំ២០១២ ជាកំណត់ ។**

ឯកសារដែលទាក់ទងពីមូលនិធិអភិវឌ្ឍបច្ចេកវិទ្យា ពាក្យស្នើសុំ សេចក្តីណែនាំក្នុងការបំពេញពាក្យស្នើសុំការគាំទ្រពីមូលនិធិ លោកលោកស្រីអាចមកទទួលនៅអាស័យដ្ឋានដែលបានដាក់ជូនខាងក្រោម ។

អាស្រ័យហេតុនេះ សូមម្ចាស់រោងចក្រ-សិប្បកម្ម និងសហគ្រាសធុនតូច និងមធ្យមទាំងអស់ជ្រាបជាព័តមាន ។

**<u>អាស័យដ្ឋានទំនាក់ទំនង:</u>**

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

លេខាធិការដ្ឋានSMEs នៃ អនុគណៈកម្មាធិការសហគ្រាសធុនតូចនិងមធ្យម

#៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ រាជធានីភ្នំពេញ

លេខទូរស័ព្ទទំនាក់ទំនង:(855)012 919 015 / 016 938 943

www.gdi.mime.gov.kh